# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តព្រះវិហារ**
លេខៈ ០៥៣/-សសរ
៦

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខៈ............
មកដល់ថ្ងៃទី ...១១ ១៦
ម៉ោង ៨:០០

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ខេត្តព្រះវិហារ ដើម្បីជម្រុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨

## អភិបាលខេត្ត

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៦៥០ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តព្រះវិហារ ក្នុងអាណត្តិទី២ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៦/៧៦០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការតែងតាំងជាអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- យោងតាមប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារ នៃការិយាល័យទាំងនោះ ។
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣២៤ ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ ស្តីពីសំណើសុំរៀបចំការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជម្រុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨ ។

## សម្រេច:

**ប្រការ ១៖-**

ត្រូវបានបង្កើត " ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ខេត្តព្រះវិហារ ដើម្បីជម្រុញការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨ " ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អ៊ុន ចាន់ដា** | អភិបាលខេត្ត | ប្រធាន |
| ២- លោក | **អ៊ុំ ឧុទ្ធី** | អភិបាលរងខេត្ត | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣- លោក | **សៀង សារិត** | ប្រធានមន្ទីរមុខងារសាធារណៈ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោក | **មុត តិសិទ្ធនា** | នាយករដ្ឋបាល សាលាខេត្ត | សមាជិក |
| ៥- លោក | **អ៊ុង ឌុទ្ធី** | អភិបាលស្រុក ត្បែងមានជ័យ | សមាជិក |
| ៦- លោក | **ឯ សារ៉ូ** | អភិបាលស្រុក រវៀង | សមាជិក |
| ៧- លោក | **ប៉ាង យៀត** | អភិបាលស្រុក គូលែន | សមាជិក |
| ៨- លោក | **ជុំ ពុយ** | អភិបាលស្រុក ជ័យសែន | សមាជិក |
| ៩- លោក | **រស់ ហេង** | អភិបាលស្រុក សង្គមថ្មី | សមាជិក |
| ១០- លោក | **នុត សោភ័ណ្ឌា** | អភិបាលក្រុង ព្រះវិហារ | សមាជិក |
| ១១- លោក | **ជា គីមសេង** | អភិបាលស្រុក ជាំក្សាន្ត | សមាជិក |
| ១២-លោក | **សុខ សាន្តតារ៉ា** | អភិបាលស្រុក ឆែប | សមាជិក |
| ១៣-លោក | **ម៉ុម សុទ្ធារ៉ា** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤-លោក | **ហួ ដារ៉ា** | អនុប្រធានធនាគារខេត្ត | សមាជិក |
| ១៥-លោក | **ម៉ក់ សម្បត្តិ** | អនុប្រធានមន្ទីរមុខងារសាធារណៈ | មន្ត្រីបង្គោល |
| ១៦-លោក | **ហុង ប្រាក់សាង** | អនុប្រធានមន្ទីរមុខងារសាធារណៈ | មន្ត្រីបង្គោល |
| ១៧-លោក | **សុវណ្ណា ចន្ទសារដ្ឋ** | មន្ត្រីការិយាល័យត្រួតពិនិត្យរដ្ឋបាល និងបៀវត្ស នៃមន្ទីរមុខងារសាធារណៈ | មន្ត្រីបង្គោល |

**ប្រការ២៖-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈខេត្តព្រះវិហារ ដើម្បីជម្រុញការអនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨ មានតួនាទី ភារកិច្ច ដូចខាងក្រោម ៖

- អង្គភាពសម្របសម្រួលអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ។
- ត្រូវរៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។
- ត្រូវរាយការណ៍អំពីវឌ្ឍនភាពឲ្យបានទៀងទាត់ រៀងរាល់ត្រីមាស មកលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨ ។

**ប្រការ៣៖-**

សេចក្តីសម្រេចលេខ ០៣៦ សសរ ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តព្រះវិហារ និងបទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤៖-**

នាយក នាយករងរដ្ឋបាល នាយកទីចាត់ការទាំង៥ អង្គភាពលទ្ធកម្ម ចំណុះរចនាសម្ព័ន្ធសាលាខេត្ត គ្រប់បណ្តាមន្ទីរ អង្គភាពជុំវិញខេត្ត និងអភិបាលក្រុង-ស្រុក ព្រមទាំងឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅខេត្តព្រះវិហារ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦

**អភិបាលខេត្ត**

**អ៊ុន ចាន់ដា**

**កន្លែងទទួល ៖**

-ក្រសួងមហាផ្ទៃ

-ក្រសួងមុខងារសាធារណៈ

"ដើម្បីជូនជ្រាប"

-ដូចប្រការ៤

"ដើម្បីជូនអនុវត្ត"

-ឯកសារ-កាលប្បវត្តិ